មើលវីដេអូ ភាគទី ១៧

# វិរតិចេតសិក ៣ (Abstinences)

១ - សម្មាវាចាចេតសិក បានដល់ វាចាប្រពៃ

២ - សម្មាកម្មន្តចេតសិក បានដល់ ការងារប្រពៃ

៣ - សម្មាអាជីវចេតសិក បានដល់ អាជីវៈប្រពៃ

ស្កេនដើម្បីមើលមេរៀន

San Sochea Official

## ២០ - សម្មាវាចាចេតសិក (Right speech)

សម្មា វទន្តិ ឯតាយាតិ = សម្មាវាចា វចីទុច្ចរិតវិរតិ វិរតិ ឈ្មោះថា សម្មាវាចា ព្រោះអត្ថថា ជាការនិយាយដោយប្រពៃនៃបុគ្គល បានដល់ ការវៀរចាកវចីទុច្ចរិត ៤។

# សម្មាវាចា ៤

១ - ចេតនាវៀរចាកការនិយាយកុហក ឆបោក

២ - ចេតនាវៀរចាកការនិយាយញុះញង់ បំបែកបំបាក់

៣ - ចេតនាវៀរចាកការនិយាយពាក្យអាក្រក់ ជេរប្រទេច

៤ - ចេតនាវៀរចាកការនិយាយរោយរាយ ឥតប្រយោជន៍

# លក្ខណាទិចតុក្កៈរបស់សម្មាវាចា

១ - វចីទុច្ចរិតវត្ថុនំ អវីតិក្កមលក្ខណា មានការមិនកន្លងវត្ថុដែល
ជាទីតាំងនៃវចីទុច្ចរិត ជាលក្ខណៈ

២ - វចីទុច្ចរិតវត្ថុតោ សង្កោចនរសា មានការថយចាកវត្ថុដែល
ជាទីតាំងនៃវចីទុច្ចរិត ជាកិច្ច

៣ - តស្ស អក្រិយបច្ចុប្បដ្ឋានា មានការមិនធ្វើនូវវចីទុច្ចរិតនោះ
ជាអាការប្រាកដ

៤ - សទ្ធាហិរោត្តប្បអប្បិច្ឆតាទិគុណបទដ្ឋានា មានគុណ គឺ
សទ្ធា ហិរិ ឱត្តប្បៈ សេចក្តីប្រាថ្នាតិច ជាដើម ជាហេតុជិត។

# ២១ - សម្មាកម្មន្តចេតសិក (Right action)

## សម្មា បវត្តោ កម្មន្តោ = សម្មាកម្មន្តោ កាយទុច្ចរិតវិរតិ

ការងារដែលប្រព្រឹត្តទៅដោយប្រពៃ ឈ្មោះថា សម្មាកម្មន្តៈ បាន ដល់ ចេតនាជាគ្រឿងវៀរចាកកាយទុច្ចរិត។

### សម្មាកម្មន្តៈ ៣

១ - ចេតនាវៀរចាក ការសម្លាប់សត្វ

២ - ចេតនាវៀរចាក ការលួចទ្រព្យគេ

៣ - ចេតនាវៀរចាក ការប្រព្រឹត្តខុសក្នុងកាម

# លក្ខណាទិចតុក្កៈរបស់សម្មាកម្មន្តៈ

១ - កាយទុច្ចរិតវត្ថូនំ អវីតិក្កមលក្ខណោ

មានការមិនកន្លងវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ជាលក្ខណៈ

២ - កាយទុច្ចរិតវត្ថុតោ សង្កោចនរសោ

មានការថយចាកវត្ថុដែលជាទីតាំងនៃកាយទុច្ចរិត ជាកិច្ច

៣ - តស្ស អក្រិយបច្ចុប្បដ្ឋានោ

មានការមិនធ្វើកាយទុច្ចរិតនោះ ជាអាការប្រាកដ

៤ - សទ្ធាហិរោត្តប្បអប្បិច្ឆតាទិគុណបទដ្ឋានោ

មានគុណ គឺ សទ្ធា ហិរិ ឱត្តប្បៈ សេចក្តីប្រាថ្នាតិចជាដើម ជាហេតុជិត។

## ២២ - សម្មាអាជីវចេតសិក (Right livelihood)

សម្មា អាជីវន្តិ ឯតេនាតិ = សម្មាអាជីវោ មិច្ឆាជីវវិរតិ វិរតិ ឈ្មោះថា សម្មាអាជីវៈ ព្រោះអត្ថថា ជាគ្រឿងចិញ្ចឹមជីវិតដោយប្រពៃនៃសត្វទាំងឡាយ បានដល់ ចេតនាវៀរចាកមិច្ឆាអាជីវៈ។

សម្មាអាជីវៈ មាន ៧ យ៉ាង គឺ វៀរចាកកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ដែលមានអាជីវៈជាហេតុ ឬមានច្រើនយ៉ាង ដោយអំណាចនៃការវៀរចាកការកុហក បោកបញ្ឆោតជាដើម។

# មិច្ឆាជីវៈ (ការចិញ្ចឹមជីវិតខុស) ៥ យ៉ាង ៖

១ - សត្ថវណិជ្ជា ការជួញគ្រឿងសស្ត្រាវុធសម្រាប់ប្រហារ គឺធ្វើគ្រឿងសស្ត្រាវុធដោយខ្លួនឯង ឬបានមកដោយហេតុឯណាមួយ ហើយលក់នូវគ្រឿងសស្ត្រាវុធនោះៗ។

២ - សត្តវណិជ្ជា ជួញមនុស្ស (សត្វ)។

៣ - មំសវណិជ្ជា ជួញសាច់ គឺចិញ្ចឹមនូវសត្វទាំងឡាយ មានជ្រូកជាដើម លុះសត្វទាំងនោះចម្រើនធំឡើងក៏សម្លាប់យកសាច់លក់។

៤ - មជ្ជវណិជ្ជា ការជួញទឹកស្រវឹង គឺផ្សំគ្រឿងណាមួយឲ្យកើតឡើងជាទឹកស្រវឹងដោយខ្លួនឯង ឬទិញគេយកមក ហើយលក់នូវទឹកស្រវឹងនោះ។

៥ - វិស វណិជ្ជា ការជួញថ្នាំពិស គឺចាត់ចែងនូវថ្នាំពិសឲ្យកើតឡើងដោយខ្លួនឯង ឬឲ្យគេផ្សំឲ្យ ឬបានមកដោយហេតុណាមួយ ហើយលក់នូវថ្នាំពិសនោះ។

# លក្ខណាទិចតុក្កៈរបស់សម្មាអាជីវៈ

១ - តិវិធកាយទុច្ចរិតចតុព្វិធវចីទុច្ចរិតវត្ថូនំ អវីតិក្កមលក្ខណោ
មានការមិនកន្លងវត្ថុដែលជាទីតាំងនៃ កាយទុច្ចរិត ៣
វចីទុច្ចរិត ៤ ជាលក្ខណៈ

២ - តេសំ វត្ថុតោ សង្កោចនរសោ
មានការថយចាកវត្ថុដែលជាទីតាំងនៃ កាយទុច្ចរិត ៣ វចីទុច្ចរិត ៤ ជាកិច្ច

៣ - តេសំ ទុច្ចរិតានំ អក្រិយបច្ចុប្បដ្ឋានោ
មានការមិនធ្វើទុច្ចរិតនោះ ជាអាការប្រាកដ

៤ - សទ្ធាហិរោត្តប្បាទិគុណបទដ្ឋានោ
មានគុណ គឺ សទ្ធា ហិរិ ឱត្តប្បៈ ជាដើម ជាហេតុជិត។

# អធិប្បាយវិរតិ ៣

ភាវៈនៃការវៀរចាកបាប ឈ្មោះថា វិរតិចេតនា ឬ ហៅថា វិរតិ មាន ៣ ប្រភេទ គឺ ៖

១- សម្បត្តវិរតិ ២-សមាទានវិរតិ ៣-សមុច្ឆេទវិរតិ

សម្បត្តវិរតិ បានដល់ ការវៀរចាកបាប ដោយអាឲ្យាស្រ័យរបស់ខ្លួនដូចក្នុងខណៈដែលកំពុងមានវិរមិតព្វវត្ថុ (វត្ថុត្រូវវៀរ) ប្រាកដចំពោះមុខហើយ ក៏មិនប្រព្រឹត្តកន្លង។

សមាទានវិរតិ បានដល់ ការវៀរចាកបាប ដោយសមាទាន (ការកាន់យក ឬរៀនយកដោយល្អ) នូវសិក្ខាបទដែលបញ្ញត្តទុក មាននិច្ចសីល និងឧបោសថសីល ជាដើម។

សមុច្ឆេទវិរតិ បានដល់ ការវៀរចាកបាប ដែលកាត់ផ្តាច់ជាសមុច្ឆេទ ដោយអរិយមគ្គ។